មូលនិធិខ្មែរសម្រាប់ការសិក្សា
Cambodian Education Excellence Foundation
ផ្តល់លទ្ធភាពសិក្សាស្មើភាពគ្នា Equal Education Opportunity for All.
12739 Knightsbridge Drive, Woodbridge, VA 22192. Tel: (703) 670-0854. ceefusa@ceefoundation.org www.ceefoundation.org

# សុន្ទរកថា (តាមវីដេអូ) របស់ វេជ្ជបណ្ឌិត ខ្មៅ សំរ៉ែ

ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា

ក្នុងពិធីផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និងរៀនពូកែ — វិជ្ជាស្ថានបច្ចេកវិទ្យាកម្ពុជា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

*សូមថ្វាយបង្គំចំពោះព្រះសង្ឃ*
*ជម្រាបសួរ លោក លោកស្រី ព្រមទាំងប្អូនៗទាំងអស់។*

*ថ្ងៃនេះជាថ្ងៃដ៏ប្រសើរថ្លៃថ្លាមួយ ក្នុងប្រវត្តិសាស្ត្ររបស់មូលនិធិខ្មែរសម្រាប់ការសិក្សា។ ក្នុងឋានៈខ្ញុំជាប្រធាន និងតំណាងគណៈកម្មាធិការ ខ្ញុំមានកិត្តិយសយ៉ាងក្រៃលែង បានចូលរួមពីចម្ងាយ ក្នុងពិធីប្រគល់អាហារូបករណ៍លើកទីមួយ ដល់និស្សិត។*

*ខ្ញុំមានអំណរ និងការសរសើរដល់ប្អូនៗ ក្នុងការខំប្រឹងប្រែង និងការតស៊ូចំពោះការសិក្សា លុះត្រាតែបានសម្រេចលទ្ធផលដ៏ប្រសើរ។ ព្រមជាមួយនឹងចំណេះវិជ្ជា សូមប្អូនរក្សាគុណសម្បត្តិ ដូចជា៖*

- *ការស្មោះត្រង់*
- *ការទទួលខុសត្រូវ*
- *ការជួយរក្សាគ្នាទៅវិញទៅមក*

*ដែលអាចជំរុញឲ្យប្អូនក្លាយទៅជាអ្នកដឹកនាំដ៏ប្រសើរមួយ នៅក្នុងសង្គម។*

*សូមប្អូនៗបណ្តុះសីលធ៌មឲ្យកើតមាននៅក្នុងខ្លួនជាដរាប ព្រោះសីលធម៌មានគុណធម៌ដ៏សំខាន់ណាស់ ដែលអាចជួយទ្រទ្រង់វិជ្ជារបស់ប្អូន ឲ្យមានពន្លឺភ្លឺចិញ្ចែង ជាស្ថាពរ។*

*សូមអរគុណ*